# ព្រះរាជក្រម

នស/រកម/០៥០៩/០០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគូវ៉ែត ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៥ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃរដ្ឋគុវ៉ែត ស្តីពីការជំរុញនិងការការពារទៅវិញ ទៅមកនូវការវិនិយោគ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋគុវ៉ែត ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគ ដែលធ្វើនៅរាជធានីភ្នំពេញ នាថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០០៩

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

៣៧.០៥០៥.៥២៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

លេខ : ៤៦៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ចិនកេន

# កិច្ចព្រមព្រៀង

## រវាង

## រាជរដ្ឋាភិបាលកម្ពុជា

## និង

## រដ្ឋាភិបាលនៃរដ្ឋគុវ៉ែត

## ស្តីពី

## ការជម្រុញ និងការការពារទៅវិញទៅមកនូវការវិនិយោគ

រាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលនៃរដ្ឋគូវ៉ែត (ចាប់ពីពេលនេះតទៅហៅថា "រដ្ឋជាប់កិច្ចសន្យា")

ក្នុងស្មារតីបង្កើតនូវលក្ខខណ្ឌអនុគ្រោះសម្រាប់ការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរវាងគ្នា និង ជាពិសេសសម្រាប់ការវិនិយោគនៃអ្នកវិនិយោគរបស់រដ្ឋជាប់កិច្ចសន្យាម្ខាង ទៅលើទឹកដីនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត

ដោយទទួលស្គាល់ថា ការជម្រុញ និងការការពារទៅវិញទៅមកនៃការវិនិយោគនេះ នឹងនាំមកនូវការផ្តួចផ្តើមនៃកំណើនធុរកិច្ច និងបង្កើនវិបុលភាពសម្រាប់រដ្ឋជាប់កិច្ចសន្យាទាំងពីរ

បានព្រមព្រៀងគ្នាដូចតទៅ :

### មាត្រា ១

### និយមន័យ

នៅក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ:

១- ពាក្យ *"វិនិយោគ"* មានន័យថា រាល់ទ្រព្យសម្បត្តិគ្រប់ប្រភេទនៅលើទឹកដីនៃរដ្ឋជាប់កិច្ចសន្យាម្ខាង ដែល ធ្វើជាម្ចាស់ ឬគ្រប់គ្រង ដោយផ្ទាល់ ឬដោយប្រយោលដោយអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត ហើយរួមបញ្ចូលនូវទ្រព្យសម្បត្តិ ឬសិទ្ធិដែលរួមមាន ឬដែលមានទ្រង់ទ្រាយជា :

(ក) ភាគហ៊ុននៃក្រុមហ៊ុន ហ៊ុន ឬការចូលរួមជាភាគហ៊ុនផ្សេងៗទៀត និង ប័ណ្ណបំណុល ប័ណ្ណកាតព្វកិច្ច និងទ្រព្យទ្រង់ទ្រាយផ្សេងទៀត ជាការប្រាក់ បំណុលនៅក្នុងក្រុមហ៊ុន និងបំណុលផ្សេងទៀត និង ប្រាក់កម្ចី និងសិទ្ធិប្រាតិភោគ ដែលបោះចេញដោយអ្នកវិនិយោគណាមួយនៃរដ្ឋជាប់កិច្ចសន្យា

(ខ) ការទាមទារប្រាក់ និងការទាមទារនូវទ្រព្យសម្បត្តិផ្សេងៗណាមួយ ឬការអនុវត្តដោយផ្អែកតាម កិច្ចសន្យាដែលមានតំលៃហិរញ្ញវត្ថុ

(គ) កម្មសិទ្ធិបញ្ញា រួមបញ្ចូលមានជាអាទិ៍ សិទ្ធិចំលង ពាណិជ្ជសញ្ញា សិទ្ធិលើប្រកាសនីយប័ត្រតក្កកម្ម គំនូរឧស្សាហកម្ម និងការកែច្នៃគំរូក្បួនខ្នាតបច្ចេកវិទ្យា ជំនាញវិជ្ជាជីវៈ ការសម្គាល់ផ្អែកពាណិជ្ជកម្ម ពាណិជ្ជនាម និង កិត្តិនាមជំនួញ

(ឃ) សិទ្ធិណាមួយដែលប្រទានដោយ ច្បាប់ កិច្ចសន្យា ឬដោយផ្អែកទៅតាមអាជ្ញាប័ណ្ណណាមួយ ឬ ការអនុញ្ញាត ដែលបានផ្តល់ឱ្យដោយច្បាប់ រួមបញ្ចូលនូវសិទ្ធិដើម្បីធ្វើបុរេសនា រុករក ទាញ យកផល ឬប្រើប្រាស់ នូវធនធានធម្មជាតិ និងសិទ្ធិដើម្បីធ្វើសកម្មភាពសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ដទៃទៀត ឬសិទ្ធិផ្តល់នូវសេវាកម្មផ្សេងៗ

(ង) ទ្រព្យរូបីយ និងអរូបីយ ចលនទ្រព្យ និងអចលនទ្រព្យដទៃទៀតណាមួយ និងសិទ្ធិលើទ្រព្យ សម្បត្តិដូចជា ភតិសន្យា កិច្ចសន្យាដាក់បញ្ចាំ សិទ្ធិឃាត់ទុកទ្រព្យបញ្ចាំ និងការសន្យាដាក់ ទ្រព្យធានា ។

ពាក្យ "*ការវិនិយោគ*" ត្រូវអនុវត្តផងដែរចំពោះ "ទិន្នផល" ដែលបានរក្សាទុកក្នុងគោលបំណងធ្វើការ វិនិយោគឡើងវិញ និងដែលបានដំណើរការពី "ការលោយ" ដែលពាក្យនេះ នឹងផ្តល់និយមន័យជាបន្តបន្ទាប់

ការផ្លាស់ប្តូរណាមួយនូវទ្រង់ទ្រាយ នៃទ្រព្យសម្បត្តិ ឬសិទ្ធិដែលបានវិនិយោគ ឬធ្វើការវិនិយោគឡើង វិញ នឹងមិនមានឥទ្ធិពលទៅលើចរិតលក្ខណៈជាការវិនិយោគឡើយ ។

២- ពាក្យ "*អ្នកវិនិយោគ*" ចំពោះរដ្ឋជាប់កិច្ចសន្យាមានន័យថា :

(ក) រដ្ឋាភិបាលនៃរដ្ឋជាប់កិច្ចសន្យា

(ខ) រូបវន្តបុគ្គល ដែលមានសញ្ជាតិ ឬភាពជាពលរដ្ឋ នៃរដ្ឋជាប់កិច្ចសន្យានោះ ដោយអនុលោមទៅ តាមច្បាប់ជាធរមានរបស់ខ្លួន

(គ) នីតិបុគ្គលណាមួយដែលបានបង្កើតឡើង ឬរៀបចំចុះបញ្ជីដោយច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋជាប់កិច្ចសន្យាដូចជា ស្ថាប័ន មូលនិធិអភិវឌ្ឍន៍ ភ្នាក់ងារ គ្រឹះស្ថានមូលនិធិ និងគ្រឹះស្ថានមានលក្ខន្តិកៈផ្សេងៗ អាជ្ញាធរ និងក្រុមហ៊ុន ។

៣- ពាក្យ *"ក្រុមហ៊ុន"* គឺមានន័យថាជានីតិបុគ្គលទោះបីបាន ឬពុំបានរៀបចំឡើងក្នុងគោលបំណងដែលមានទំនាក់ទំនងទៅនឹងការចំណេញប្រាក់ និងទោះបីជាគ្រប់គ្រង ឬដោយឯកជន ឬ ដោយរដ្ឋាភិបាលក្តី ដែលបានបង្កើតឡើងតាមច្បាប់នៃរដ្ឋជាប់កិច្ចសន្យា ឬមានម្ចាស់ ឬគ្រប់គ្រងផ្ទាល់ដោយអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យា និងរួមបញ្ចូលទាំង សាជីវកម្ម ឯកាធិកម្ម សហកម្មសិទ្ធិ ឯកកម្មសិទ្ធិ សាខា សម្ព័ន្ធអាជីវកម្ម សមាគម ឬអង្គការប្រហាក់ប្រហែលផ្សេងទៀត ។

៤- ពាក្យ *"ទិន្នផល"* មានន័យថា ចំណូលបានមកពីការវិនិយោគដោយមិនគិតដល់ទ្រង់ទ្រាយនៃការវិនិយោគដែលត្រូវបានផ្តល់ឱ្យ និងជាពិសេសរាប់បញ្ចូលមានជាអាទិ៍ ប្រាក់ចំណេញ ការប្រាក់ ប្រាក់ចំណេញមូលធនភាគលាភ កំរៃ និងថ្លៃគ្រប់គ្រង ជំនួយបច្ចេកទេស ឬការចំណាយ ឬថ្លៃឈ្នួលផ្សេងទៀត និងការទូទាត់សងជាវត្ថុ ដោយពុំគិតដល់ប្រភេទនៃរបស់ទាំងនោះឡើយ ។

៥- ពាក្យ *"រំលាយ"* មានន័យថា សកម្មភាពដែលបានចាត់ចែងឡើងក្នុងគោលបំណងដើម្បីបញ្ឈប់មួយផ្នែក ឬ ទាំងស្រុងនៃវិនិយោគ

៦- ពាក្យ *"ទឹកដី"* មានន័យថា:

(ក) ចំពោះព្រះរាជាណាចក្រកម្ពុជា មានន័យថា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដែនដីទាំងអស់ ដែនសមុទ្រ បាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ និងដែនអាកាសដែលព្រះរាជាណាចក្រកម្ពុជាមានអធិបតេយ្យភាព ឬ មានសិទ្ធិគ្រប់គ្រងតាមផ្លូវច្បាប់ ស្របតាមច្បាប់ជាតិ និង ច្បាប់អន្តរជាតិ

(ខ) ចំពោះ គូវ៉ែត មានន័យថា ទឹកដីនៃរដ្ឋគូវ៉ែត ដែលរួមបញ្ចូលទាំងតំបន់នៃដែនសមុទ្រ ដោយអនុលោមតាមច្បាប់អន្តរជាតិ ត្រូវបានឬនាពេលក្រោយមក ត្រូវបានកំណត់នៅក្រោមច្បាប់គូវ៉ែតថា ជាតំបន់ដែលគូវ៉ែតអាចអនុវត្តនូវ អធិបតេយ្យភាព ឬ សិទ្ធិគ្រប់គ្រងតាមផ្លូវច្បាប់។

៧- ពាក្យ *"រូបិយប័ណ្ណដែលអាចប្តូរបានដោយសេរី"* មានន័យថា រូបិយប័ណ្ណណាមួយដែលមូលនិធិរូបិយវត្ថុអន្តរជាតិបានកំណត់ ពីរយៈពេលមួយទៅរយៈពេលមួយ ថាជារូបិយប័ណ្ណដែលអាចប្រើបានដោយសេរី អនុលោមទៅតាមមាត្រានៃកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិ និង ការធ្វើវិសោធនកម្មណាមួយនោះ

៨- ពាក្យ "មិនមានការពន្យារពេល" មានន័យថារយៈពេលមួយដែលជាធម្មតាត្រូវការសម្រាប់ការបំពេញនូវបែបបទចាំបាច់សំរាប់ការផ្ទេរនូវការទូទាត់សង ។ រយៈពេលនោះត្រូវចាប់ផ្តើមនៅថ្ងៃដែលសំណើសុំផ្ទេរត្រូវបានធ្វើឡើង ដោយមិនឱ្យលើសពីរយៈពេលមួយខែ ។

## មាត្រា ២

## ការជម្រុញ និងការការពារនៃវិនិយោគ

១- រដ្ឋជាប់កិច្ចសន្យានីមួយៗត្រូវលើកទឹកចិត្ត និងបង្កលក្ខណៈអនុគ្រោះដល់ការវិនិយោគរបស់អ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតនៅក្នុងទឹកដីរបស់ខ្លួន នូវសិទ្ធិក្នុងការប្រើប្រាស់អំណាចដែលប្រទានដោយច្បាប់ ចំពោះការយល់ព្រមសម្រាប់ការវិនិយោគនោះ ។

២- ការវិនិយោគដែលធ្វើឡើងដោយអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាមួយ ត្រូវទទួលបានគ្រប់ពេលវេលានូវប្រព្រឹត្តិកម្មដោយត្រឹមត្រូវ និងសមធម៌ ហើយត្រូវទទួលបាននូវការការពារ និងសន្តិសុខពេញលេញនៅក្នុងទឹកដីនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត តាមបែបទដែលមានសង្គតភាពទៅនឹងអ្វីដែលបានទទួលស្គាល់ដោយគោលការណ៍នៃច្បាប់អន្តរជាតិ និងបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ។ រដ្ឋជាប់កិច្ចសន្យានឹងពុំធ្វើឱ្យខូចប្រយោជន៍ដោយវិធានការមិនសមហេតុផល ឬរើសអើងចំពោះការគ្រប់គ្រង ការថែទាំ ការប្រើប្រាស់ ការទទួលផល ឬការចាត់ចែងវិនិយោគរបស់អ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតនៅក្នុងទឹកដីខ្លួនឡើយ ។ រដ្ឋជាប់កិច្ចសន្យានីមួយៗត្រូវពិនិត្យមើលនូវបណ្តាកាតព្វកិច្ច ឬការសន្យាណាមួយដែលមានទំនាក់ទំនងទៅនឹងការវិនិយោគរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

៣- នៅពេលដែលបានបង្កើតឡើងរួចហើយ ការវិនិយោគរបស់អ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាណាមួយ ពុំតម្រូវឱ្យបំពេញកាតព្វកិច្ចបន្ថែមដែលអាចនាំឱ្យខូចប្រយោជន៍ដល់ភាពស្ថិតស្ថេររបស់គេ ឬ ធ្វើអោយ

ប៉ះពាល់ជាអវិជ្ជមានដល់ការប្រើប្រាស់ ការគ្រប់គ្រង ការកាន់កាប់ ការធ្វើអាជីវកម្ម ការពង្រីក ការលក់ ឬការចាត់ចែងផ្សេងទៀតនោះឡើយ ។

## មាត្រា ៣
## ប្រព្រឹត្តិកម្មនៃការវិនិយោគ

១- ទាក់ទងទៅនឹងការប្រើប្រាស់ ការគ្រប់គ្រង ការកាន់កាប់ ការធ្វើអាជីវកម្ម ការពង្រីក និងការលក់ ឬការចាត់ចែងផ្សេងទៀតនៃវិនិយោគ ដែលបានធ្វើឡើងដោយអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត រដ្ឋជាប់កិច្ចសន្យានីមួយៗត្រូវយល់ព្រមផ្តល់នូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនតិចជាងអ្វី ដែលខ្លួនបានយល់ព្រមនៅក្នុងស្ថានភាពដូចគ្នាទៅឱ្យការវិនិយោគនៃអ្នកវិនិយោគរបស់ខ្លួន ឬអ្នកវិនិយោគនៃតតិយជនណាមួយ ពោលគឺ ត្រូវផ្តល់នូវភាពអនុគ្រោះណាមួយដែលមានលក្ខណៈប្រសើរជាងទៅឱ្យការវិនិយោគទាំងនោះ។

២- ទោះជាយ៉ាងណាក្តី បញ្ញត្តិនៃមាត្រានេះពុំត្រូវបានបកស្រាយថា ជាការចាប់បង្ខំឱ្យរដ្ឋជាប់កិច្ចសន្យាម្ខាងផ្តល់ឱ្យទៅអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត នូវផលប្រយោជន៍នៃប្រព្រឹត្តិកម្ម ការយោគយល់ ឬអត្ថប្រយោជន៍ពិសេសណាមួយដែលជាផលបានមកពី :

(ក) សហព័ន្ធគយ សហគមន៍សេដ្ឋកិច្ច តំបន់ពាណិជ្ជកម្មសេរី សហព័ន្ធរូបិយវត្ថុ ឬទម្រង់ទ្រាយផ្សេងទៀតនៃការសម្របសម្រួលសេដ្ឋកិច្ចតំបន់ ឬ កិច្ចព្រមព្រៀងអន្តរជាតិប្រហាក់ប្រហែលដែលរដ្ឋជាប់កិច្ចសន្យាម្ខាងណាមួយ កំពុងស្ថិតនៅជាសមាជិក ឬនឹងក្លាយទៅជាសមាជិក

(ខ) កិច្ចព្រមព្រៀងអន្តរជាតិ តំបន់ ឬទ្វេភាគី ឬកិច្ចព្រមព្រៀងប្រហាក់ប្រហែល ឬច្បាប់ក្នុងស្រុកដែលមានទំនាក់ទំនងមួយផ្នែក ឬ ទាំងស្រុងទៅនឹងការប្រមូលពន្ធ។

## មាត្រា ៤
## សំណងសម្រាប់ការខាតបង់

១- លើកលែងករណីមាត្រា ៦ ត្រូវបានយកមកអនុវត្ត ការវិនិយោគដែលធ្វើឡើងដោយអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងណាមួយដែលទទួលរងនូវការខាតដោយសារតែសង្គ្រាម ឬជំលោះអាវុធ ការប្រកាសប្រទេសជាតិស្ថិតក្នុងភាពអាសន្ន បដិវត្តន៍ ភាពចលាចលស៊ីវិល ការបះបោរ កុប្បកម្ម ឬព្រឹត្តិការណ៍

ប្រហាក់ប្រហែលនៅលើទឹកដីនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត អ្នកវិនិយោគត្រូវតែទទួលបាននូវការយល់ព្រមពីរដ្ឋជាប់កិច្ចសន្យាជាម្ចាស់ផ្ទះ នូវប្រព្រឹត្តិកម្មដូចជាការធ្វើឱ្យដូចដើមវិញនូវសំណង ការទូទាត់សំណង ឬដំណោះស្រាយផ្សេងទៀតនូវភាពអនុគ្រោះមិនតិចជាងអ្វីដែលរដ្ឋជាប់កិច្ចសន្យាជាម្ចាស់ផ្ទះ បានយល់ព្រមផ្តល់ដល់អ្នកវិនិយោគរបស់ខ្លួន ឬអ្នកវិនិយោគនៃតតិយរដ្ឋណាមួយ ពោលគឺត្រូវផ្តល់នូវភាពអនុគ្រោះណាមួយដែលមានលក្ខណៈប្រសើរជាងទៅឱ្យអ្នកវិនិយោគនោះ ។

២- ដោយមិនប៉ះពាល់ដល់វាក្យខ័ណ្ឌទី១ អ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងដែលស្ថិតនៅក្នុងហេតុការណ៍ណាមួយនៃវាក្យខ័ណ្ឌនេះ ដែលបានរងការខាតបង់នៅក្នុងទឹកដីនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត បណ្តាលមកពី :

(ក) ការរឹបអូសទ្រព្យសម្បត្តិនៃការវិនិយោគរបស់ខ្លួន ឬចំណែកនៃទ្រព្យសម្បត្តិទាំងនោះ ដោយកំលាំងទ័ព ឬ ដោយអាជ្ញាធរ

(ខ) ការបំផ្លាញនូវការវិនិយោគ ឬចំណែកនៃការវិនិយោគនោះ ដោយកំលាំងទ័ព ឬដោយអាជ្ញាធរ ដែលមិនមែនជាមូលហេតុបណ្តាលមកពីការប្រយុទ្ធគ្នា ឬ មិនបានតម្រូវដោយស្ថានភាពជាចាំបាច់

នឹងត្រូវទទួលបាននូវការធ្វើឱ្យដូចដើមឡើងវិញ ឬការទូទាត់សំណងដោយឆាប់រហ័ស គ្រប់ចំនួន និងមានប្រសិទ្ធិភាព សម្រាប់ការខូចខាត ឬការខាតបង់ដែលគេបានទទួលរងទោះបីក្នុងករណីណាមួយក៏ដោយ ។

## មាត្រា ៥
## ការដកហូត

១- (ក) ការវិនិយោគទាំងឡាយដែលបានធ្វើឡើងដោយអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យានៅលើទឹកដីនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត ពុំត្រូវបានធ្វើជាតូបនីយកម្ម ដកហូត ដកសិទ្ធិជាម្ចាស់ ឬប្រកាន់យកនូវវិធានការដោយផ្ទាល់ ឬដោយប្រយោល ដែលមានឥទ្ធិពលសមមូលទៅនឹងការធ្វើជាតូបនីយកម្ម ការដកហូត ឬដកសិទ្ធិជាម្ចាស់ (ចាប់ពីពេលនេះតទៅជារួមហៅថា "ការដកហូត") ដោយរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតឡើយ លើកលែងតែដើម្បីផលប្រយោជន៍សាធារណៈ ដែលមានគោលបំណងពាក់ព័ន្ធទៅនឹងតម្រូវការផ្ទៃក្នុងនៃរដ្ឋជាប់កិច្ចសន្យានោះ ដោយភ្ជាប់នូវសំណងឆាប់រហ័ស គ្រប់ចំនួន និងមានប្រសិទ្ធិភាព និងក្នុងលក្ខខណ្ឌថា វិធានការដូចគ្នានេះត្រូវបានប្រកាន់

យកលើមូលដ្ឋានពុំមានការរើសអើង ហើយអនុលោមទៅនឹងតម្រូវការនៃនីតិវិធីទូទៅតាមច្បាប់ជាធរមាន ។

(ខ) សំណងដូចនេះត្រូវមានចំនួនស្មើនឹងតំលៃនៃទីផ្សារបច្ចុប្បន្ននៃការវិនិយោគដែលបានដកហូត និងត្រូវគណនាដោយអនុលោមទៅតាមគោលការណ៍ នៃការវាយតម្លៃដែលទទួលស្គាល់ជាអន្តរជាតិ លើមូលដ្ឋានតំលៃត្រឹមត្រូវនៃទីផ្សារ នៃការវិនិយោគដែលបានដកហូតនាពេលភ្លាមៗមុនការដកហូតត្រូវបានប្រកាន់យក ឬការដកហូតនោះត្រូវបានដឹងឮជាសាធារណៈ ដោយយកមួយណាដែលឆាប់ជាង (ចាប់ពីពេលនេះតទៅហៅថា "ថ្ងៃកំណត់តំលៃ")។ សំណងបែបនេះត្រូវបានគណនាទៅជារូបិយប័ណ្ណដែលអាចប្តូរបានដោយសេរី ហើយដែលអ្នកវិនិយោគអាចជ្រើសរើសនៅថ្ងៃកំណត់តំលៃ និងត្រូវរួមបញ្ចូលផងដែរនូវការប្រាក់តាមអត្រាពាណិជ្ជកម្មបង្កើតឡើងលើមូលដ្ឋានទីផ្សារ ដែលទោះជាយ៉ាងណាក៏ដោយ ក៏មិនត្រូវតិចជាងអត្រាការប្រាក់ LIBOR ជាទូទៅ ឬសមមូល ដោយគិតពីថ្ងៃដែលបានដកហូត រហូតដល់ថ្ងៃទូទាត់សង។

២- ដើម្បីមានភាពប្រាកដប្រជា ការដកហូតត្រូវរួមបញ្ចូលនូវស្ថានភាពនាពេលដែលរដ្ឋជាប់កិច្ចសន្យាបានដកហូតទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ឬសហគ្រាសដែលបានចុះបញ្ជី ឬបង្កើតឡើងតាមច្បាប់ជាធរមាននៅក្នុងទឹកដីរបស់ខ្លួនដែលអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតបានធ្វើការវិនិយោគ រួមបញ្ចូលតាមរយៈភាពជាម្ចាស់ភាគហ៊ុនស្តុក ប័ណ្ណភាគពួកិច្ច ឬសិទ្ធិដទៃទៀត ឬផលប្រយោជន៍នៃភាគកម្ម ។

៣- ចំពោះគោលបំណងនៃកិច្ចព្រមព្រៀងនេះ៖ ពាក្យថា "ការដកហូត" មានរាប់បញ្ចូលផងដែរនូវវិធានការជាអន្តរាគមន៍ ឬជាវិធានការតាមបទប្បញ្ញត្តិដោយរដ្ឋជាប់កិច្ចសន្យាដូចជាការបង្កក ឬ ការរាំងខ្ទប់នូវការវិនិយោគដែលស្របច្បាប់ និង សកម្មភាពរបស់គេ ។

## មាត្រា ៦

## ការផ្ទេរទូទាត់សង ទាក់ទងទៅនឹងការវិនិយោគ

១- រដ្ឋជាប់កិច្ចសន្យាម្ខាងត្រូវធានាដល់អ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតនូវការផ្ទេរការវិនិយោគដោយសេរី និង ការទូទាត់សងដែលពាក់ព័ន្ធទាំងក្នុង និងក្រៅទឹកដីរបស់ខ្លួន ។

២- ការផ្ទេរទូទាត់សងតាមវាក្យខណ្ឌ (១)ត្រូវអនុវត្តដោយពុំមានការពន្យាពេលឬដាក់កំហិត លើកលែងតែក្នុងករណីការទូទាត់សងជាវត្ថុ និងដោយរូបិយប័ណ្ណដែលអាចប្តូរបានដោយសេរី ។ ប្រសិនបើមានការពន្យាពេលដែលជាតម្រូវការចាំបាច់នោះ អ្នកវិនិយោគដែលរងផលប៉ះពាល់ មានសិទ្ធិទទួលបាននូវការប្រាក់សម្រាប់រយៈពេលនៃការពន្យាពេលនោះ ។

៣- រដ្ឋជាប់កិច្ចសន្យាម្ខាងត្រូវយល់ព្រមផ្តល់ជូនអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតនូវប្រព្រឹត្តិកម្មពាក់ព័ន្ធទៅនឹងការផ្ទេរការទូទាត់សង ដែលមានភាពអនុគ្រោះមិនតិចជាងអ្វី ដែលខ្លួនបានយល់ព្រមផ្តល់ជូនអ្នកវិនិយោគនៃតតិយរដ្ឋ ។

## មាត្រា ៧

## ឧបាទេសកម្ម

១- ក្នុងករណីដែលរដ្ឋជាប់កិច្ចសន្យា ឬភ្នាក់ងារដែលខ្លួនបានតែងតាំង (ភាគីអ្នកប៉ះប៉ូវសំណង) បានធ្វើការទូទាត់សងក្រោមរូបភាពជាការប៉ះប៉ូវសំណង ឬការធានា ដែលខ្លួនត្រូវទទួលបន្ទុកចំពោះការវិនិយោគនៅលើទឹកដីនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត (រដ្ឋជាម្ចាស់ផ្ទះ) រដ្ឋជាម្ចាស់ផ្ទះត្រូវទទួលស្គាល់ :

(ក) ការផ្ទេរសិទ្ធិនៃភាគីអ្នកប៉ះប៉ូវសំណង ដោយច្បាប់ ឬតាមប្រតិបត្តិការផ្លូវច្បាប់នូវសិទ្ធិទាំងអស់ដែលកើតចេញពីការវិនិយោគនោះ

(ខ) សិទ្ធិរបស់ភាគីអ្នកប៉ះប៉ូវសំណងដើម្បីអនុវត្តសិទ្ធិនោះ និងការទាមទារ បំពេញនូវរាល់កាតព្វកិច្ចទាក់ទងនឹងការវិនិយោគដោយផ្អែកទៅនឹងឧបាទេសកម្ម ។

២- ភាគីអ្នកប៉ះប៉ូវសំណងមានសិទ្ធិទទួលបាននូវប្រព្រឹត្តិកម្មដូចគ្នានៅគ្រប់កាលៈទេសៈចំពោះ :

(ក) សិទ្ធិការទាមទារដែលទទួលបាន និងកាតព្វកិច្ចដែលត្រូវទទួលបន្ទុក ដោយផ្អែកទៅតាមការផ្ទេរសិទ្ធិដូចមានចែងក្នុងវាក្យខណ្ឌទី១ ខាងលើ

(ខ) ការទូទាត់សងដែលត្រូវទទួលបានដោយអនុលោមទៅតាមសិទ្ធិ និងការទាមទារទាំងឡាយនោះ

ដូចអ្នកវិនិយោគដើមដំបូង ដែលមានសិទ្ធិទទួលបាន ដោយផ្អែកទៅតាមកិច្ចព្រមព្រៀងនេះ ទាក់ទងទៅនឹងការវិនិយោគដែលមានការពាក់ព័ន្ធ ។

## មាត្រា ៨

## ដំណោះស្រាយវិវាទរវាងរដ្ឋជាប់កិច្ចសន្យា និងអ្នកវិនិយោគ

១- វិវាទដែលកើតឡើងរវាងរដ្ឋជាប់កិច្ចសន្យា និងអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតទាក់ទងទៅនឹងការវិនិយោគរបស់ខ្លួននៅលើទឹកដីនៃរដ្ឋជាប់កិច្ចសន្យាជាម្ចាស់ផ្ទះ ត្រូវដោះស្រាយដោយមិត្តភាព ប្រសិនជាអាចធ្វើទៅបាន ។

២- ក្នុងករណីវិវាទពុំអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយខែ គិតចាប់ពីថ្ងៃដែលភាគីណាមួយនៃវិវាទមានសំណូមពរដោះស្រាយដោយមិត្តភាព តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតនោះ វិវាទនឹងត្រូវបានលើកឡើងដើម្បីស្វែងរកដំណោះស្រាយតាមជម្រើសនៃភាគីអ្នកវិនិយោគដែលមានវិវាទ តាមរយៈមធ្យោបាយណាមួយដូចខាងក្រោម :

(ក) តុលាការមានសមត្ថកិច្ចនៃរដ្ឋជាប់កិច្ចសន្យាជាម្ចាស់ផ្ទះ ដើម្បីសម្រេច

(ខ) មជ្ឈត្តវិនិច្ឆ័យអន្តរជាតិ ដោយអនុលោមទៅវាក្យខ័ណ្ឌនៃមាត្រានេះ

៣- ក្នុងករណីអ្នកវិនិយោគបានជ្រើសរើសដំណោះស្រាយវិវាទទៅមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ អ្នកវិនិយោគត្រូវបន្តផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរសម្រាប់វិវាទទៅអង្គភាពណាមួយដូចតទៅ:

(ក) ១).មជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ ដែលបានបង្កើតឡើងដោយផ្អែកតាមអនុសញ្ញាស្តីពីដំណោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និងជនជាតិនៃរដ្ឋនានាដែលបានចុះហត្ថលេខានៅទីក្រុងវ៉ាស៊ីនតោនកាលពីថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៦៥ (អនុសញ្ញាវ៉ាស៊ីនតោន) ក្នុងករណីរដ្ឋជាប់កិច្ចសន្យាទាំងពីរជាភាគីនៃអនុសញ្ញាវ៉ាស៊ីនតោន ហើយអនុសញ្ញាវ៉ាស៊ីនតោននោះ អាចយកមកអនុវត្តន៍បានចំពោះវិវាទនេះ

២)មជ្ឈមណ្ឌលក្រោមវិធានគ្រប់គ្រងយន្តការផ្តល់សេវាកម្មជាបន្ថែម ដើម្បីដំណើរការតាមបែបបទរដ្ឋបាលនូវទំរង់ការបណ្តឹងដោយលេខាធិការដ្ឋាននៃមជ្ឈមណ្ឌល ប្រសិនបើរដ្ឋជាប់កិច្ចសន្យានៃអ្នកវិនិយោគ ឬរដ្ឋជាប់កិច្ចសន្យាដែលមានវិវាទ ជាភាគីនៃអនុសញ្ញាវ៉ាស៊ីនតោន ប៉ុន្តែមិនមែនរដ្ឋទាំងពីរទេ ។

(ខ) តុលាការអាជ្ញាកណ្តាលបង្កើតឡើងតាមវិធានអាជ្ញាកណ្តាល ("វិធាន") នៃគណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) ដែលវិធានទាំងនោះអាចកែសម្រួលបាន

ដោយភាគីវិវាទ (អាជ្ញាធរតែងតាំងដោយផ្អែកតាមមាត្រា ៧ នៃវិធាន គឺជាអគ្គលេខាធិការនៃមជ្ឈមណ្ឌល)

(គ) តុលាការអាជ្ញាកណ្តាល បង្កើតឡើងដោយផ្អែកទៅតាមវិធាននៃអាជ្ញាកណ្តាលរបស់ស្ថាប័នអាជ្ញាកណ្តាលណាមួយ ដោយមានការព្រមព្រៀងគ្នាទៅវិញទៅមកនោះរវាងភាគីវិវាទ។

៤- ថ្វីបើមានករណីពិត ដែលអ្នកវិនិយោគបានលើកសំណើវិវាទទៅដាក់ជូនអាជ្ញាកណ្តាលទទួលបន្ទុកតាមវាក្យខណ្ឌ ៣ រួចហើយក៏ដោយ អ្នកវិនិយោគនោះអាចមុនពេលដែលដាក់ឱ្យដំណើរការ ឬក្នុងពេលដំណើរការរបស់ស្ថាប័នអាជ្ញាកណ្តាលស្វែងរកពីតុលាការយុត្តិធម៌ ឬ រដ្ឋបាលនៃរដ្ឋជាប់កិច្ចសន្យាដែលជាភាគីមានវិវាទនូវអធិបញ្ញាបណ្តោះអាសន្នជាជំនួយដើម្បីការពារនូវសិទ្ធិ និងផលប្រយោជន៍របស់ខ្លួនក្នុងលក្ខខណ្ឌដែលពុំមានបញ្ចូលនូវសំណើការទាមទារឱ្យមានការទូទាត់សងនូវការខូចខាតណាមួយទេនោះ ។

៥- ក្នុងដំណើរការជំនុំជម្រះក្តីតាមផ្លូវតុលាការ អាជ្ញាកណ្តាល ឬផ្សេងពីនោះ ឬក្នុងករណីអនុវត្តនូវការសម្រេចណាមួយទាក់ទងទៅនឹងវិវាទវិនិយោគរវាងរដ្ឋជាប់កិច្ចសន្យា និង អ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត រដ្ឋជាប់កិច្ចសន្យាពុំត្រូវប្រើប្រាស់ក្នុងនាមជាចុងចោទ នូវអភ័យឯកសិទ្ធិនៃអធិបតេយ្យភាពរបស់ខ្លួនឡើយ ។ ការលើកមតិជំទាស់ ឬសិទ្ធិនៃការលើកឡើងនូវមតិណាមួយ មិនអាចផ្អែកលើមូលដ្ឋានដែលអ្នកវិនិយោគពាក់ព័ន្ធបានទទួលរួចហើយ ឬនឹងទទួលបានដោយផ្អែកតាមកិច្ចសន្យាធានារ៉ាប់រង នូវការប៉ះប៉ូវសង ឬសំណងផ្សេងទៀតសម្រាប់ទាំងស្រុង ឬមួយផ្នែក នៃការខូចខាតដែលទទួលរងពីភាគីទីបីណាមួយ អ្នកណាមួយទោះបីជាសាធារណៈ ឯកជនក៏ដោយ រាប់បញ្ចូលទាំងរដ្ឋជាប់កិច្ចសន្យាផ្សេងទៀត និង អនុផ្នែក ភ្នាក់ងារ ឬ ភ្នាក់ងារសហការីរបស់គេឡើយ ។

## មាត្រា ៩

## ដំណោះស្រាយវិវាទរវាងរដ្ឋជាប់កិច្ចសន្យា

១- រដ្ឋជាប់កិច្ចសន្យាតាមលទ្ធភាពដែលអាចធ្វើបាន ត្រូវដោះស្រាយវិវាទពាក់ព័ន្ធទៅនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះតាមរយៈការពិគ្រោះយោបល់ ឬតាមរយៈផ្លូវទូត ។

២- ក្នុងករណីវិវាទ ពុំអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីថ្ងៃដែលការពិគ្រោះយោបល់ ឬការ ដោះស្រាយតាមផ្លូវទូតដែលបានស្នើឡើងដោយរដ្ឋជាប់កិច្ចសន្យាមួយ និង លើកលែងតែរដ្ឋ

ជាប់កិច្ចសន្យាបានយល់ព្រមជាលាយលក្ខណ៍អក្សរ រដ្ឋជាប់កិច្ចសន្យាម្ខាង តាមការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលផ្ញើជូនរដ្ឋជាប់កិច្ចសន្យាម្ខាងទៀត អាចលើកវិវាទទៅតុលាការអាជ្ញាកណ្តាល AD-HOC ដោយអនុលោមទៅតាមបញ្ញត្តិជាបន្តបន្ទាប់នៃមាត្រានេះ ។

៣- តុលាការអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងដូចតទៅ : រដ្ឋជាប់កិច្ចសន្យានីមួយៗត្រូវតែងតាំងសមាជិកម្នាក់ ហើយសមាជិកទាំងពីររូបត្រូវព្រមព្រៀងគ្នាជ្រើសរើសជនជាតិនៃរដ្ឋទីបីដើម្បីឱ្យធ្វើជាប្រធាននៃតុលាការអាជ្ញាកណ្តាលដែលត្រូវតែងតាំងដោយរដ្ឋជាប់កិច្ចសន្យាទាំងពីរ ។ សមាជិកនោះត្រូវបានតែងតាំងក្នុងរយៈពេលពីរខែ ហើយប្រធានត្រូវតែងតាំងក្នុងរយៈពេលបួនខែ គិតចាប់ពីថ្ងៃដែលរដ្ឋជាប់កិច្ចសន្យាមួយ បានជូនដំណឹងទៅរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតពីបំណងចង់លើកសំណើវិវាទទៅតុលាការអាជ្ញាកណ្តាល។

៤- ក្នុងករណីអំឡុងពេលដែលបានបញ្ជាក់ក្នុងវាក្យខណ្ឌ ៣ ខាងលើ ពុំត្រូវបានអនុវត្តទេ រដ្ឋជាប់កិច្ចសន្យានីមួយៗប្រសិនជាពុំមានការសម្របសម្រួលណាផ្សេងទៀតនោះ អាចអញ្ជើញប្រធាននៃតុលាការយុត្តិធម៌អន្តរជាតិដើម្បីឱ្យទទួលការតែងតាំងដ៏ចាំបាច់នេះ ។ ក្នុងករណីប្រធានតុលាការយុត្តិធម៌អន្តរជាតិជាជនជាតិនៃរដ្ឋជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារនេះបាន អនុប្រធានតុលាការយុត្តិធម៌អន្តរជាតិត្រូវបានអញ្ជើញដើម្បីទទួលការតែងតាំងដ៏ចាំបាច់នេះ ។ ក្នុងករណីដែលអនុប្រធានជាជនជាតិនៃរដ្ឋជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញការងារនេះបាន សមាជិកនៃតុលាការយុត្តិធម៌អន្តរជាតិដែលមានឋានៈបន្ទាប់ និងដែលមិនមែនជាជនជាតិនៃរដ្ឋជាប់កិច្ចសន្យាណាមួយ ត្រូវបានអញ្ជើញឱ្យទទួលការតែងតាំងដ៏ចាំបាច់នេះ ។

៥- តុលាការអាជ្ញាកណ្តាលត្រូវធ្វើការសម្រេចក្តីរបស់ខ្លួនដោយបោះឆ្នោតយកសំឡេងភាគច្រើន ។ សេចក្តីសម្រេចនេះ ត្រូវធ្វើដោយអនុលោមទៅតាមកិច្ចព្រមព្រៀងនេះ និងវិធាននៃច្បាប់អន្តរជាតិដែលបានទទួលស្គាល់ និងត្រូវតែជាសេចក្តីសម្រេចចុងក្រោយដែលរដ្ឋជាប់កិច្ចសន្យាទាំងពីរត្រូវតែគោរពអនុវត្ត ។ រដ្ឋជាប់កិច្ចសន្យានីមួយៗទទួលបន្ទុកលើការចំណាយរបស់សមាជិក ក៏ដូចជាការចំណាយចំពោះអ្នកតំណាងរបស់ខ្លួននៅក្នុងដំណាក់ការជំរះក្តីអាជ្ញាកណ្តាល ។ ការចំណាយរបស់ប្រធានក៏ដូចជាការចំណាយផ្សេងទៀតនៃដំណាក់ការជំរះក្តីអាជ្ញាកណ្តាល ត្រូវជាបន្ទុកស្មើគ្នានៃរដ្ឋជាប់កិច្ចសន្យាទាំងពីរ ។ ទោះជាយ៉ាងណាក្តី តុលាការអាជ្ញាកណ្តាលតាមឆន្ទានុសិទ្ធរបស់ខ្លួនអាចណែនាំឱ្យចំណែកខ្ពស់ ឬចំណែកទាំងអស់នៃថ្លៃចំណាយត្រូវ

ទទួលបន្ទុកដោយរដ្ឋជាប់កិច្ចសន្យាណាមួយ ។ នៅគ្រប់ទិដ្ឋភាពផ្សេងទៀតតុលាការអាជ្ញាកណ្តាលត្រូវកំណត់នីតិវិធីផ្ទាល់របស់ខ្លួន ។

## មាត្រា ១០

## ទំនាក់ទំនងរវាងរដ្ឋជាប់កិច្ចសន្យា

បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះនឹងអនុវត្តដោយមិនចំណុះទៅនឹងអត្ថិភាពជាទំនាក់ទំនងកិច្ចការទូត ឬកុងស៊ុល រវាងរដ្ឋជាប់កិច្ចសន្យាឡើយ ។

## មាត្រា ១១

## ការអនុវត្តវិធានផ្សេងទៀត

ក្នុងករណីដែលច្បាប់នៃរដ្ឋជាប់កិច្ចសន្យាណាមួយ ឬ កាតព្វកិច្ចក្រោមច្បាប់អន្តរជាតិដែលកំពុងមានបច្ចុប្បន្ន ឬបានបង្កើតនាពេលក្រោយរវាងរដ្ឋជាប់កិច្ចសន្យា ជាការបន្ថែមពីលើកិច្ចព្រមព្រៀងនេះ មានកំណត់អំពីវិធាន ទោះបីមានលក្ខណៈទូទៅ ឬដោយឡែក បានផ្តល់សិទ្ធិដល់ការវិនិយោគធ្វើឡើងដោយអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតនូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះប្រសើរជាងអ្វីដែលបានផ្តល់ក្នុងកិច្ចព្រមព្រៀងនេះ វិធានដូចនេះ ក៏នឹងអនុវត្តដូចគ្នាក្នុងការផ្តល់នូវភាពអនុគ្រោះប្រសើរជាង ជូនអ្នកវិនិយោគបន្ថែមលើកិច្ចព្រមព្រៀងនេះផងដែរ។

## មាត្រា ១២

## ការចូលជាធរមាន

កិច្ចព្រមព្រៀងនេះត្រូវតែមានការផ្តល់សច្ចាប័ន និងចូលជាធរមាននៅថ្ងៃនៃការប្តូរឱ្យគ្នា ទៅវិញទៅមកនូវឯកសារនៃការផ្តល់សច្ចាប័ន ។

កិច្ចព្រមព្រៀងនេះត្រូវអនុវត្តន៍សំរាប់រាល់ការវិនិយោគដែលធ្វើឡើងដោយអ្នកវិនិយោគនៃរដ្ឋជាប់កិច្ចសន្យាម្ខាងណាមួយនៅលើទឹកដីនៃរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតដែលបានយល់ព្រមឱ្យវិនិយោគ ស្របតាមច្បាប់ និងបទប្បញ្ញត្តិរបស់

ខ្លួន ទោះបីការវិនិយោគបានធ្វើនៅមុន ឬក្រោយការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ប៉ុន្តែមិនអនុវត្តន៍សំរាប់វិវាទវិនិយោគដែលបានកើតឡើង ឬការតវ៉ាណាមួយទាក់ទងនឹងការវិនិយោគ ដែលបានដោះស្រាយរួចហើយនៅមុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះឡើយ។

## មាត្រា ១៣
## រយៈពេល និង ការបញ្ចប់

(១) កិច្ចព្រមព្រៀងនេះត្រូវបន្តមានសុពលភាពសំរាប់រយៈពេលម្ភៃឆ្នាំ និងក្រោយពេលនោះត្រូវចាត់ទុកថាមានវិសាលភាពជាស្វ័យប្រវត្តិលើកលែងតែរដ្ឋជាប់កិច្ចសន្យាម្ខាងណាមួយ បានផ្តល់ទៅរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ និងពីឆន្ទៈចង់បញ្ចប់កិច្ចព្រមព្រៀងនេះ ។ កិច្ចព្រមព្រៀងត្រូវកំណត់បញ្ចប់ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃទទួលបាននូវការជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការបញ្ចប់នេះ ។

(២) ថ្វីបើមានការបញ្ចប់កិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមវាក្យខ័ណ្ឌ (១) នៃមាត្រានេះក៏ដោយ កិច្ចព្រមព្រៀងត្រូវមានសុពលភាពសំរាប់រយៈពេលម្ភៃឆ្នាំជាបន្តទៀតគិតចាប់ពីថ្ងៃបញ្ចប់ ចំពោះការវិនិយោគដែលបានធ្វើ ឬ បានទិញយកមកកាន់កាប់នៅមុនថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះ ។

(៣) កិច្ចព្រមព្រៀងនេះអាចធ្វើវិសោធនកម្ម ដោយការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងរដ្ឋជាប់កិច្ចសន្យាទាំងពីរ ។ ការធ្វើវិសោធនកម្មណាមួយ នឹងអាចចូលជាធរមានទៅបាន នៅពេលដែលភាគីរដ្ឋជាប់កិច្ចសន្យាម្ខាងបានជូនដំណឹង ទៅរដ្ឋជាប់កិច្ចសន្យាម្ខាងទៀតថា បានបំពេញរួចរាល់ហើយនូវតម្រូវការដើម្បីការចូលជាធរមាននៃការធ្វើវិសោធនកម្មនេះ ។

ជាសក្ខីភាពនៃកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវពីរដ្ឋាភិបាលរៀងៗខ្លួនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើនៅ រាជធានីភ្នំពេញ នាថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៨ ចំនួន ០២ ច្បាប់ដើម ដោយច្បាប់នីមួយៗជាភាសាខ្មែរ ភាសាអារ៉ាប់ និង ភាសាអង់គ្លេស មានតំលៃគតិយុត្តិដូចគ្នា ។

ក្នុងករណីមានការបកស្រាយ ផ្សេងគ្នានោះ ភាសាអង់គ្លេស និងត្រូវបានយកមកធ្វើជាសំអាង។

តំណាងរាជរដ្ឋាភិបាល
កម្ពុជា

..........................................

ចម ប្រសិទ្ធ
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

តំណាងរដ្ឋាភិបាល
នៃរដ្ឋគុវ៉ែត

..........................................

មូស្តាហ្វា ហ្សាស៊ីម អាល់_ហ្សៃម៉ាលី
រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

# *AGREEMENT*

## *BETWEEN THE ROYAL GOVERNMENT OF CAMBODIA*

## *AND*

## *THE GOVERNMENT OF STATE OF KUWAIT*

## *FOR THE ENCOURAGEMENT AND RECIPROCAL PROTECTION OF INVESTMENTS*

The Royal Government of Cambodia and the Government of the State of Kuwait, (hereinafter referred to as the "Contracting States");

Desiring to create favorable conditions for the development of economic cooperation between them and in particular for investments by investors of one Contracting State in the territory of the other Contracting State;

Recognizing that the encouragement and reciprocal protection of such investments will be conducive to the stimulation of business initiative and to the increase of prosperity in both Contracting States;

Have agreed as follows:

*Article 1*

***Definitions***

For the purpose of this Agreement:

1. The term 'investment' shall mean every kind of asset in the territory of one Contracting State that is owned or controlled directly or indirectly by an investor of the other Contracting State, and includes assets or rights consisting or taking the form of:

(a) a company shares, stocks, and other forms of equity participation, and bonds, debentures, and other forms of debt interests in a company, and other debts and loans and securities issued by any investor of a Contracting State;

(b) claims to money and claims to any other assets or performance pursuant to a contract having an economic value;

(c) intellectual property rights, including, but not limited to, copyrights, trademarks, patents, industrial designs and patterns and technical processes, know-how, trade secrets, trade names and goodwill;

(d) any right conferred by law, contract or by virtue of any licenses or permits granted pursuant to law, including rights to prospect, explore, extract, or utilize natural resources, and rights to undertake other economic or commercial activities or to render services;

(e) any other tangible and intangible, movable and immovable property, and any related property rights, such as leases, mortgages, liens and pledges.

The term "investment" shall also apply to "returns" retained for the purpose of re-investment and to proceeds from "liquidation" as these terms are defined hereinafter.

Any change in the form in which assets or rights are invested or reinvested shall not affect their character as investments.

2. The term "investor" with respect to a Contracting State shall mean:

(a) the government of that Contracting State;

(b) a natural person holding the nationality or citizenship of that Contracting State in accordance with its applicable laws;

(c) any legal person constituted or incorporated under the laws and regulations of that Contracting State, such as institutions, development funds, agencies, foundations and other statutory establishments and authorities, and companies.

3. The term "company" shall mean any legal entity, whether or not organized for the purpose of pecuniary gain, and whether privately or governmentally owned or controlled, which is constituted under the laws of a Contracting State or is owned or effectively controlled by investors of a Contracting State, and includes corporations, trusts, partnerships, sole proprietorships, branches, joint ventures, associations or other similar organizations.

4. The term "returns" shall mean amounts yielded by an investments, irrespective of the form in which they are paid, and in particular, though not exclusively, include profits, interest, capital gains, dividends, royalties, and management fees, technical assistance or other payments or fees, and payments in kind, regardless of its type.

5. The term "liquidation" shall mean any disposal effected for the purpose of completely or partly giving up an investment.

6. The term "territory" shall mean:

(a) with respect to the Kingdom of Cambodia shall means the territory of The Kingdom of Cambodia including all land territory, the territorial sea, its seabed and subsoil and airspace

over which Cambodia has sovereign rights or jurisdiction in accordance with international and national law.

(b) with respect to the State of Kuwait shall means the territory of the State of Kuwait including any area beyond the territorial sea which in accordance with international law has been or may hereafter be designated, under the laws of Kuwait, as an area over which Kuwait may exercise sovereign rights or jurisdiction.

7 The term "freely convertible currency" shall mean any currency that the International Monetary Fund determines, from time to times, as freely usable currency in accordance with the Articles of Agreement of the International Monetary Fund and any amendment thereto.

8. The term "without delay" shall mean such period as is normally required for the completion of necessary formalities for the transfer of payments. The said period shall commence on the day on which the requests for transfer has been submitted and may on no account exceed one month.

*Article 2*

*Promotion and Protection of Investments*

1. Each Contracting State shall encourage and create favourable conditions for investments of investors of the other Contracting State in its territory, and, subject to its right to exercise powers conferred by its laws, shall admit such investments.

2. Investments of investors of a Contracting State shall at all time be accorded fair and equitable treatment and shall enjoy full protection and security in the territory of the other Contracting state in a manner consistent with recognized principles of International Law and the provisions of this Agreement. Neither Contracting State

shall in any way impair by unreasonable or discriminatory measures the management, maintenance, use, enjoyment or disposal of investments in the territory by investors of the other Contracting State. Each Contracting State shall observe any obligation of commitment it may have entered into with regard to investments of investors of the other Contracting State.

3. Once established, investments of investors of either Contracting State shall not be subject to additional performance requirements which may be detrimental to their viability or adversely affect their use, management, conduct, operation, expansion, sale or other disposition.

*Article 3*

*__Treatment of Investments__*

1. With respect to the use, management, conduct, operation, expansion and sale or other disposition of investments made in its territory by investors of the other Contracting State, each Contracting State shall accord treatment not less favorable than that it accords, in similar situations, to investments of its own investors or investors of any third state, whichever is most favorable to those investments.

2. However, the provisions of this Article shall not be construed so as to oblige one Contracting State to extend to the investors of the other Contracting State the benefit of any treatment, preference or privilege resulting from:

   (a) any customs union, economic union, free trade area, monetary union, or any other form of regional economic arrangement or other similar international agreement, to which either of the Contracting States is or may become a party;

   (b) any international, regional or bilateral agreement or other similar arrangement or any domestic legislation relating wholly or mainly to taxation.

### *Article 4*

### ***Compensation for Losses***

1. Except where Article 6 applies, when investments made by an investor or either Contracting State suffers a loss owing to war or other armed conflict, a state of national emergency, revolt, civil disturbances, insurrection, riot or other similar events in the territory of the other Contracting State, he shall be accorded by the latter Contracting State, treatment, as regards restitution, indemnification, compensation or other settlement, not less favorable than that the latter Contracting State accords to its own investors or investors of any third state, whichever is most favorable to the investor.

2. Without prejudice to paragraph 1, investors of one Contracting State who in any of the events referred to in that paragraph suffers a loss in the territory of the other Contracting State resulting from:

   (a) requisitioning of its investments or part thereof by its forces or authorities;

   (b) destruction of its investment or part thereof by its forces or authorities which was not caused in combat action or was not required by the necessity of the situation.

   shall be accorded restitution or compensation which in either case shall be prompt, adequate and effective for the damages or losses they have suffered.

### *Article 5*

### ***Expropriation***

1. (a) Investments made by investor of any of the Contracting States in the territory of the other Contracting State shall not be

nationalized, expropriated, dispossessed or subjected to direct or indirect measures having effect equivalent to nationalization, expropriation or dispossession (hereinafter collectively referred to as "expropriation") by the other Contracting State except for a public purpose related to the internal needs of that Contracting State and against prompt, adequate and effective compensation and on condition that such measures were taken on a non-discriminatory basis and in accordance with due process of law of general application.

(b) Such compensation shall amount to the actual value of the expropriated investments and shall be determined and computed in accordance with internationally recognized principles of valuation on the basis of the fair market value of the expropriated investment at the time immediately before the expropriatory action was taken or the impending expropriation became publicly known, whichever is earlier (hereinafter referred to as the "valuation date"). Such compensation shall be calculated in a freely convertible currency to be chosen by the investor, on the basis of the prevailing market rate of exchange for that currency on the valuation date and shall include interest at a commercial rate established on a market basis, however, in no event less than the prevailing LIBOR - rate of interest or equivalent, from the date of expropriation until the date of payment.

2. For further certainty, expropriation shall include situations where a Contracting State expropriates the assets of a company or enterprise that is incorporated or established under the laws in force in its own territory in which an investor of the other Contracting State has an investment, including through the ownership of shares, stock, debentures or other rights or interests.

3. For the purposes of this Agreement, the term "expropriation" shall also include any interventions or regulatory measures by a Contracting State such as the freezing or blocking of any lawful investment and its activities.

## *Article 6*

## *Transfer of Payments Related to Investments*

1. Each Contracting State shall guarantee to investors of the other Contracting State the free transfer of investments and payments in connection with them into and out of its territory.

2. Transfers of payments under paragraph (1) shall be affected without delay or restrictions and, except in the case of payments in kind and, in a freely convertible currency. In case of such delay in effecting the required transfers, the investor affected shall be entitled to receive interest for the period of such delay.

3. Each Contracting State shall accord investors of the other Contracting State treatment not less favorable than that accorded to investors of any third State in connection with the transfers.

## *Article 7*

## *Subrogation*

1. If a Contracting State or its designated agency (the "Indemnifying Party"), makes a payment under an indemnity or guarantee it has assumed in respect of an investment in the territory of the other Contracting State (the "Host State"), the Host State shall recognize:

   (a) the assignment to the Indemnifying Party by law or by legal transaction of all the rights and claims resulting from such an investment;

(b) the right of the Indemnifying Party to exercise all such rights and enforce such claims and assume all obligations related to the investment by virtue of subrogation.

2. The Indemnifying Party shall be entitled in all circumstances to the same treatment in respect of:

(a) the rights and claims acquired and the obligations assumed by it by virtue of the assignment referred to in paragraph 1 above;

(b) any payments received in pursuance of those rights and claims.

As the original investor was entitled to receive by virtue of this Agreement in respect of the investment concerned.

*Article 8*

*Settlement of Disputes Between a Contracting State and an Investor*

1. Disputes arising between a Contracting State and an investor of the other contracting State in respect of an investment of the latter in the territory of the former shall, as far as possible, be settled amicably.

2. If such deputes cannot be settled within a period of six months from the date at which either party to the dispute requested amicable settlement by delivering a notice in writing to the other party, the dispute shall be submitted for resolution, at the election of the investor party to the dispute, through one of the following means:

(a) the competent court of the host Contracting State for decision;

(b) to international arbitration in accordance with the following paragraphs of this Article.

3. In the event that an investor elects to submit the dispute for resolution to international arbitration, the investor shall further provide its consent in writing for the dispute to be submitted to one of the following bodies;

(a) (1) The International Centre for Settlement of Investment Disputes ("the Centre"), established pursuant to the Convention on the Settlement of Investment Disputes between States and Nationals or other States opened for signature at Washington, 18 March 1965 (the " Washington Convention"), if both Contracting States are parties to the Washington Convention and the Washington Convention in applicable to the dispute;

(2) The Centre, under the rules governing the Additional Facilities for the Administration of Proceedings by the Secretariat of the Centre (the "Additional Facility Rules"), if the Contracting State of the investor or the Contracting State to the dispute, but not both, is a party to the Washington Convention;

(b) an arbitral tribunal established under the Arbitration Rules (the "Rules") of the United Nations Commission on International Trade Law (UNCITRAL), as those Rules may be modified by the parties to the dispute (the Appointing Authority referred to under Article 7 of the Rules shall be the Secretary General of the Centre);

(c) an arbitral tribunal constituted pursuant to the arbitration rules of any arbitral institution mutually agreed upon between the parties to the dispute.

4. Notwithstanding the fact that the investor may have submitted a dispute to binding arbitration under paragraph 3, it may, prior to the institution of the arbitral proceeding or during the proceeding, seek before the judicial or administrative tribunals of the Contracting State that is a party to the dispute, interim injunctive

relief for the preservation of its rights and interests, provided it does not include request for payment of any damages.

5. In any proceedings, judicial, arbitral or otherwise or in an enforcements of any decision or award, concerning an investment dispute between a Contracting State and an investor of the other Contracting State, a Contracting State shall not assert, as a defense, its sovereign immunity. Any counterclaim or right of set-off may not be based on the fact that the investor concerned has received or will receive, pursuant to an insurance contract, indemnification or other compensation for all or part of its alleged damages from any third party whomsoever, whether public or private, including such other Contracting State and its subdivisions, agencies or instrumentalities.

*Article 9*

Settlement of Dispute Between the Contracting States

1. The Contracting States shall, as far as possible, settle any dispute concerning the interpretation or application of this Agreement through consultations or other diplomatic channels.

2. If the dispute has not been settled within six months following the date on which such consultations or other diplomatic channels were requested by either Contracting State and unless the Contracting States otherwise agree in writing, either Contracting State may, by written notice to the other Contracting State, submit the dispute to and *ad hoc* arbitral tribunal in accordance with the following provisions of this Article.

3. The arbitral tribunal shall be constituted as follow: each Contracting State shall appoint one member, and these two members shall agree upon a national of a third state as Chairman of the arbitral tribunal to be appointed by the two Contracting States. Such member shall be appointed within two months, and such Chairman within four months, from the date on which either Contracting State has informed the other Contracting State that it intends to submit the dispute to an arbitral tribunal.

4. If the periods specified in paragraph 3 above have not been complied with, either Contracting State may, in the absence of any other arrangement, invite the President of the International Court of Justice to make the necessary appointments. If the President of the International Court of Justice is a national of either Contracting State or if he is otherwise prevented from discharging the said function, the Vice-President of the International Court of Justice shall be invited to make the necessary appointments. If the Vice-President of the International Court of Justice is a national of either Contracting State or if he, too, is prevented from discharging the said function, the member of the International Court of Justice next in seniority who is not a national of either Contracting State shall be invited to make the necessary appointments.

5. The arbitral tribunal shall take its decision by a majority of votes. Such decision shall be made in accordance with this Agreement and such recognized rules of international law as may be applicable and shall be final and binding on both Contracting States. Each Contracting State shall bear the costs of the member of the arbitral tribunal appointed by that Contracting State, as well as the costs for its representation in the arbitration proceedings. The expenses of the Chairman as well as any other costs of the arbitration proceedings shall be borne in equal parts by the two Contracting States. However, the arbitral tribunal may, at its discretion, direct that a higher proportion or all of such costs be paid by one of the Contracting States. In all other respects, the arbitral tribunal shall determine its own procedure.

*Article 10*

***<u>Relations Between Contracting States</u>***

The provisions of this Agreement shall apply irrespective of the existence of diplomatic or consular relations between the Contracting States.





### *Article 11*

### *Application of Other Rules*

If the legislation of either Contracting State or obligations under international law existing at present or established hereafter between the Contracting States, in addition to this Agreement, contain rules, whether general or specific, entitling investments by investors of the other Contracting State to a treatment more favorable than is provided for by this Agreement, such rules shall to the extent that they are more favorable to the investor prevail over this Agreement.

### *Article 12*

### *Entry into Force*

This Agreement shall be subjected to ratification and shall enter into force on the date of exchange of Instruments of Ratification.

This Agreement shall apply to all investments made by investors of either Contracting State in the territory of the other Contracting State, accepted as such in accordance with its laws and regulations, whether made before or after the coming into force of this Agreement, but shall not apply to any dispute concerning an investment which arose, or any claim concerning an investment which was settled before its entry into force.

### *Article 13*

### *Duration and Termination*

(1) This Agreement shall remain in force for a period of 20 years and thereafter it shall be deemed to have been automatically extended unless either Contracting State gives to the other Contracting State a written notice of its intention to terminate the Agreement. The Agreement shall stand terminated one year from the date on receipt of such written notice.

(2) Notwithstanding termination of this Agreement pursuant to paragraph (1) of this Article, the Agreement shall continue to be effective for a further period of 20 years from the date of its termination in respect of investments made or acquired before the date of termination of this Agreement.

(3) This Agreement may be amended by written agreement between the two Contracting States. Any amendment shall enter into force when each Contracting State has notified the other that it has completed all requirements for entry into force of such amendment.

IN WITNESS WHEREOF, the undersigned, duly authorised thereto by their respective Governments, have signed this Agreement.

Done at Phnom Penh on this day of Shaban 1429 H corresponding to 4th day of August 2008 in two originals, each in the Khmer, Arabic and English languages, all texts being equally authentic. In case of any divergence, the English text shall prevail.

| | |
|---|---|
| For the Royal Government of Cambodia | For the Government of the State of Kuwait |
| CHAM PRASIDH<br>Senior Minister, Minister of Commerce<br>Vice-Chairman of the Council for the Development of Cambodia | Mustafa Jasim Al-Shamali<br>Minster of Finance |